**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

**ប្រ.ក/លេខ ០២.២២៦/០៧ គជប.អគ្គ.៣ស**

ភ្នំពេញ ថ្ងៃទី ០១ ខែ កុម្ភៈ ឆ្នាំ ២០០៧

# គ.ជ.ប បាននិងកំពុងដំណើរការផលិតសន្លឹកឆ្នោត

សន្លឹកឆ្នោតចំនួន ៨.៨៤១.៥៥០ សន្លឹក សម្រាប់ប្រើក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី២ ឆ្នាំ ២០០៧ បាននិងកំពុងដំណើរការផលិតដោយរោងពុម្ពមួយឈ្មោះថា “ លីវ៉ាន់ហុង ” ដែលមានអាសយដ្ឋានផ្ទះលេខ ៩ ផ្លូវ ៣៨៥ សង្កាត់បឹងកក់ទី១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។

ឯកឧត្តម ទេព នីថា បានមានប្រសាសន៍ប្រាប់ដល់ តំណាងគណបក្សនយោបាយ អ្នកសង្កេតការណ៍បោះឆ្នោត និង អ្នកសារព័ត៌មាន នៅក្នុងពិធីបង្ហាញទីតាំងរោងពុម្ព នៅព្រឹកថ្ងៃទី១ ខែ កុម្ភៈ ឆ្នាំ ២០០៧ ថា គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) បានបោះពុម្ពសន្លឹកឆ្នោតមានប្រភេទផ្សេងៗគ្នាទូទាំង ១៦២១ ឃុំ សង្កាត់ ។ ការខុសគ្នានៃសន្លឹកឆ្នោតនេះ ប្រែប្រួលទៅតាមចំនួនគណបក្សនយោបាយដែលបានចុះបញ្ជីបេក្ខជននៅក្នុង គឃ/សប និងលំដាប់លេខរៀងដាក់នៅលើសន្លឹកឆ្នោត ។ ឯកឧត្តមបានបញ្ជាក់ថា សន្លឹកឆ្នោតដែលប្រើនៅថ្ងៃបោះឆ្នោតមានចំនួនស្មើនឹងចំនួនអ្នកបោះឆ្នោតនៅក្នុងបញ្ជីឈ្មោះអ្នកបោះឆ្នោតផ្លូវការឆ្នាំ ២០០៦ ចំនួន ៧.៧៩៩.៣៧១ សន្លឹក ហើយសល់ពីនេះគឺជាសន្លឹកឆ្នោតត្រៀមបំរុង សម្រាប់ការិយាល័យបោះឆ្នោតនីមួយៗ ដែលមានចំនួនពី ៥០ ទៅ ៩៩ សន្លឹក ។

ចំពោះការចំណាយទៅលើការផលិតសន្លឹកឆ្នោតនេះ ត្រូវចំណាយអស់ថវិកាប្រមាណ ៨០០.០០០$ (ប្រាំបីរយពាន់ដុល្លារសហរដ្ឋអាមេរិក) ។

ឯកឧត្តមអគ្គលេខាធិការបានបញ្ជាក់អំពីការផលិតសន្លឹកឆ្នោតនោះថា មានការបែងចែកជាតារាងតាមដានការងារច្បាស់លាស់ កំណត់ពេលម៉ោង ក្នុងការបោះពុម្ពសន្លឹកឆ្នោត និងការជញ្ជូនសន្លឹកឆ្នោត ពីផ្នែកមួយទៅ ផ្នែកមួយនៅក្នុងរោងពុម្ពនេះ ហើយនៅពេលវេចខ្ចប់មុននឹងបញ្ជូនទៅ គខ/កប នីមួយៗ គ.ជ.ប នឹងបញ្ជូនមន្ត្រីមកត្រួតពិនិត្យម្តងទៀត ។ ដូចនេះ គ.ជ.ប មានវិធានការហ្មត់ចត់ណាស់នៅក្នុងដំណើរការបោះពុម្ពសន្លឹកឆ្នោតនេះ ។

ព័ត៌មានបន្ថែមសូមទំនាក់ទំនង : ទូរស័ព្ទលេខ: ០២៣ ២១៤ ៣៧៤ / ០១២ ៨៥៥ ០១៧ E-mail: necinfo@forum.org.kh, Web-site : www.necelect.org.kh